# កិច្ចប្រជុំស្តីពី
# "ទិវាសង្គមស៊ីវិល"

ប្រធានបទ

**ភាពជាដៃគូប្រកបដោយបរិយាប័ន្នសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ**
**និងប្រកបដោយចីរភាព**

ថ្ងៃអង្គារ ១៤កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ,ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩

**រៀបចំដោយ: អង្គការគណៈកម្មាធិការប្រតិបត្តិដើម្បីកម្ពុជា**(CCC)

---

# សុន្ទរកថាបើកកិច្ចប្រជុំ
# "ទិវាសង្គមស៊ីវិល"
## ដោយឯកឧត្តម ម៉ុន ហុន អនុរដ្ឋលេខាធិការ នៃក្រសួងមហាផ្ទៃ

- **គណៈអធិបតី!**
- **ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក !**

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានមកចូលរួមជាមួយនឹង ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ក្នុងកិច្ចប្រជុំស្តីពី " **ទិវាសង្គមស៊ីវិល** " ក្រោមប្រធានបទ **ភាពជាដៃគូប្រកបដោយបរិយាប័ន្នសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងប្រកបដោយចីរភាព** នាឱកាសដ៏ថ្លៃថ្លានេះ។

ក្នុងនាម **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវគារវកិច្ច និងសូមស្វាគមន៍ចំពោះវត្តមានរបស់គណៈអធិបតី **ឯកឧត្តម** លោកជំទាវ អស់លោក លោកស្រី តំណាងក្រសួងស្ថាប័ននានា នៃរាជរដ្ឋាភិបាល តំណាងស្ថានទូតនានា ដៃគូអភិវឌ្ឍន៍ សមាគម អង្គការមិនមែនរដ្ឋាភិបាល តំណាងសហគមន៍មូលដ្ឋាន វិស័យឯកជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលបានឆ្លៀតពេលវេលាដ៏មមាញឹក ដើម្បីចូលរួមក្នុងកិច្ចប្រជុំស្តីពី " **ទិវាសង្គមស៊ីវិល** " ដែលរៀបចំឡើងដោយអង្គការគណៈកម្មាធិការប្រតិបត្តិដើម្បីកម្ពុជា(CCC) នាឱកាសនេះ។

- **ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

ខ្ញុំយល់ថា "**ទិវាសង្គមស៊ីវិល**"នេះ ជាបរិយាកាស និងជាឱកាសដ៏ល្អមួយសម្រាប់យើងទាំងអស់គ្នា បានជួបជុំគ្នារវាងអ្នកពាក់ព័ន្ធនានា សមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និង

បរទេស ព្រមទាំងដៃគូអភិវឌ្ឍន៍នានា តំណាងសហគមន៍មូលដ្ឋាន និងវិស័យឯកជន ដើម្បីសិក្សាស្វែងយល់ និងរៀនសូត្រពីគ្នាទៅវិញទៅមក សំដៅរួមចំណែកក្នុងការអភិវឌ្ឍន៍ និងពង្រឹងនូវកិច្ចសហការគ្នាក្នុងភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល។

រាជរដ្ឋាភិបាលកម្ពុជា ក៏បានទទួលស្គាល់ផងដែរថា ការរីកចម្រើន និងការអភិវឌ្ឍនាពេលបច្ចុប្បន្ននេះ គឺពិតជាមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ក្នុងនោះមានដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការសង្គមស៊ីវិល។ អង្គការសង្គមស៊ីវិលទាំងក្នុងស្រុក និងបរទេសបានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ និងគាំទ្រដល់សេវាសង្គមនៅតាមមូលដ្ឋានជនបទ និងសហគមន៍ដាច់ស្រយាល និងធ្វើសកម្មភាពនៅគ្រប់រាជធានី ខេត្ត ក្នុងវិស័យសំខាន់ៗដែលពាក់ព័ន្ធនឹងសេដ្ឋកិច្ច សង្គម នៅក្នុងប្រទេសកម្ពុជា។ អង្គការសង្គមស៊ីវិល ក៏បានចូលរួមផងដែរក្នុងការតស៊ូមតិឲ្យមានកំណែទម្រង់ជាតិ ដើម្បីលើកកម្ពស់សុខភាព ការអប់រំ អភិបាលកិច្ច សិទ្ធិមនុស្ស ប្រព័ន្ធច្បាប់ សេវាសង្គម បរិស្ថាន សុខុមាលភាពស្ត្រី និងកុមារ នេះបើយោងតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីសង្គមស៊ីវិលនៅកម្ពុជា កាលពីឆ្នាំ២០១១។ រហូតមកដល់បច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានការអភិវឌ្ឍលើគ្រប់វិស័យ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តខ្វាត់ខ្វែង និងមានកំណើនសេដ្ឋកិច្ចដ៏រឹងមាំមួយក្នុងចំណោមប្រទេសនានាក្នុងតំបន់ និងពិភពលោក ជាពិសេសនៅក្នុងឆ្នាំ២០១៧ កន្លងទៅនេះ កម្ពុជាសម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ចប្រមាណ ៧,១% ហើយនៅឆ្នាំ២០១៨នេះ ត្រូវបានប៉ាន់ប្រមាណថានឹងសម្រេចបានអត្រាកំណើនក្នុងរង្វង់៧%។ ការសម្រេចបាននូវអត្រាកំណើនសេដ្ឋកិច្ចជាប់ៗគ្នា ក្នុងរយៈពេលជិត២(ពីរ)ទស្សវត្សនេះ បានធ្វើឲ្យកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមធ្វើការអបអរសាទរចំពោះ សមិទ្ធផល និងការខិតខំប្រឹងប្រែងរបស់អង្គការមិនមែនរដ្ឋាភិបាល សមាគម និងការគាំទ្រយ៉ាងសកម្មពីសំណាក់ដៃគូអភិវឌ្ឍន៍ ក្នុងការជំរុញការអភិវឌ្ឍ ប្រកបដោយ ចីរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ទិវាសង្គមស៊ីវិល ជាឱកាសមួយដែលសម្រាប់ការជួបជុំក្រុមអង្គការសង្គមស៊ីវិល ក៏ជាដើម្បីចែករំលែកនូវបទពិសោធន៍ ទស្សនៈទានផ្សេងៗសម្រាប់ការអភិវឌ្ឍកម្ពុជា។ ជាមួយនេះដែរ ខ្ញុំសង្ឃឹមថា ទិវាសង្គមស៊ីវិលនេះ នឹងអាចក្លាយជា ព្រឹត្តិការណ៍ប្រចាំឆ្នាំមួយសម្រាប់អង្គការសង្គមស៊ីវិល ដើម្បីចែករំលែកសមិទ្ធផលផ្សេងៗ រៀបរាប់នូវរឿងរ៉ាវជោគជ័យរបស់ខ្លួន ក៏ដូចជាពិភាក្សាអំពីបញ្ហាសំខាន់ៗ មួយចំនួន។ លើសពីនេះ ទិវាសង្គមស៊ីវិល ក៏នឹងជាវេទិកាមួយដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការក្នុងចំណោមអង្គការសង្គមស៊ីវិល ដៃគូ និងរាជរដ្ឋាភិបាលផងដែរ។ ក្នុងរយៈពេលកន្លងមក អង្គការមិនមែនរដ្ឋាភិបាល បានខិតខំប្រឹងប្រែងចូលរួមក្នុងដំណើរការ ភាពជាដៃគូប្រកបដោយបរិយាប័ន្នក្នុងគោលនយោបាយសកល ថ្នាក់តំបន់ និងថ្នាក់ក្រោមជាតិ ដូចជា គោលការណ៍សកលស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) គោលនយោបាយរបស់អាស៊ាន គោលនយោបាយស្តីពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា (CSDGs) គោលនយោបាយស្តីពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (NSDP) គោលនយោបាយស្តីពីកម្មវិធីអនុវត្តដំណាក់កាលទី៣ (IP3) គោលនយោបាយស្តីពីការអនុវត្តក្របខណ្ឌគណនេយ្យភាពសង្គម (ISAF) និងគោលនយោបាយ

ផ្សេងទៀត។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាទីរាប់អាន!**

រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកអង្គការសង្គមស៊ីវិល គឺជាដៃគូដ៏មានសារៈសំខាន់ក្នុងការចូលរួមចំណែកកសាងប្រទេសជាតិ និងបានលើកទឹកចិត្តតាមគ្រប់រូបភាពដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនានាដែលកំពុងធ្វើសកម្មភាពបម្រើប្រជាពលរដ្ឋនៅទូទាំងប្រទេស ក្នុងកិច្ចដំណើរការស្តារអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងការគាំពារលើកស្ទួយការអនុវត្តគោលការណ៍ប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ។ ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ២០១៥ បានកំណត់សិទ្ធ និងកាតព្វកិច្ចក្នុងការបង្កើត និងដំណើការរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីការពារប្រយោជន៍ស្របច្បាប់របស់អង្គការសង្គមស៊ីវិល និងការពារប្រយោជន៍សាធារណៈ។

ក្នុងការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល រហូតមកដល់ពេលបច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមានចំនួនសរុប **៥.៣៨៦** (សមាគមចំនួន**២.១៣៥** និងអង្គការមិនមែនរដ្ឋាភិបាលចំនួន**៣.២៥១**)។ បន្ទាប់ពីច្បាប់នេះចូលជាធរមាន គិតមកដល់ត្រឹមដំណាច់ខែកុម្ភៈ ឆ្នាំ២០១៩នេះ មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានសុំចុះបញ្ជីនៅក្រសួងមហាផ្ទៃ មានចំនួនសរុប**៧៨៨** (សមាគមចំនួន**៣៥៨** និងអង្គការមិនមែនរដ្ឋាភិបាលចំនួន**៤៣០**)។

រយៈពេលកន្លងមក ក្រសួងមហាផ្ទៃក៏បានធ្វើសេចក្តីជូនដំណឹងចំនួន០២(ពីរ)លើករួចមកហើយដើម្បីឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បំពេញកាតព្វកិច្ចស្របតាមបទប្បញ្ញត្តិច្បាប់កំណត់ ពាក់ព័ន្ធនឹងការផ្តល់ព័ត៌មានគណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការ និងការផ្តល់របាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំមកក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ តាមរយៈការជូនដំណឹងនេះមានតែសមាគម និងអង្គការមិនមែនរដ្ឋាភិបាល **ប្រហែលជិត ២.០០០(ពីរពាន់)ប៉ុណ្ណោះ** ដែលបានបំពេញកាតព្វកិច្ចនៅក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៧។

ទន្ទឹមនេះ គិតត្រឹមពាក់កណ្តាលខែមីនា ឆ្នាំ២០១៩នេះ គឺមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានតែចំនួន**៤៩៩ប៉ុណ្ណោះ** ដែលបានផ្តល់ព័ត៌មានគណនីដែលត្រូវបើកសម្រាប់កិច្ចប្រតិបត្តិការ និងផ្តល់របាយការណ៍សកម្មភាព និងរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ២០១៨ ជូនមកក្រសួងមហាផ្ទៃ ក្នុងនោះមានសមាគម ចំនួន**១២២** និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន**៣៧៧** ។

ដោយយោងតាមស្មារតីនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងផ្អែកតាមរបាយការណ៍ដៃរបស់គូអភិវឌ្ឍន៍ថា និងអង្គការសង្គមស៊ីវិល ក្រសួងមហាផ្ទៃ ក៏បានរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល បានចំនួនពីរលើករួចមកហើយរួមមានៈ

**<u>លើកទី១</u>** នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដើម្បីពិនិត្យឡើងវិញនូវស្ថានភាពកិច្ចសហប្រតិបត្តិការរវាងភាគីទាំងពីរ និងដើម្បីកំណត់អំពីបញ្ហាប្រឈមនានារបស់អង្គការសង្គមស៊ីវិលទាំងអស់ និងដើម្បីស្វែងរកវិធានការដោះស្រាយ។ នៅក្នុងវេទិកានោះ មានអ្នកចូលរួមប្រមាណ**៤០០(បួនរយ)នាក់** មកពីគ្រប់ក្រសួង ស្ថាប័ននានា នៃរាជរដ្ឋាភិបាលកម្ពុជា មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលចំនួន២០០។

ផ្អែកតាមលទ្ធផល នៃកិច្ចពិភាក្សានៅក្នុងវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដែលបានលើកឡើងអំពីកង្វល់ និងសំណូមពរសំខាន់ៗ មួយចំនួន រាជរដ្ឋាភិបាលបានដាក់ចេញសេចក្តីសម្រេចលេខ៨៤ សសរ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្តីពីការបង្កើតក្រុមការងាររបស់រាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលដោះស្រាយសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិល ដែលមានសមាសភាពមកពីក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ទន្ទឹមនេះផងដែរ ក្រសួងមហាផ្ទៃក៏បានដាក់ចេញនូវសេចក្តីណែនាំលេខ០៤០ សណន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ព្រមទាំងសហគមន៍នានានៅមូលដ្ឋាន។

**<u>លើកទី២</u>** នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ នៅក្នុងវេទិកានោះ មានអ្នកចូលរួមប្រមាណ **៤០០(បួនរយ)នាក់** មកពីគ្រប់ក្រសួង ស្ថាប័ននានា នៃរាជរដ្ឋាភិបាលកម្ពុជា មន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិល ចំនួន២០០។

លទ្ធផល នៃវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី២ មានសំណូមពរ និងអនុសាសន៍សំខាន់ៗ មួយចំនួនដែលត្រូវបន្តដោះស្រាយ រួមមានដូចខាងក្រោម៖

១-ក្រសួងពាក់ព័ន្ធគួរមានការសម្របសម្រួល និងការឆ្លើយតបជាលក្ខណៈប្រព័ន្ធ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាស្វ័យប្រវត្តិ (Automated and Online Technology) ដើម្បីកាត់បន្ថយភាពស្មុគស្មាញនៃកិច្ចការរដ្ឋបាល។

២-ស្នើសុំរាជរដ្ឋាភិបាលគួរនិរាករណ៍នូវប្រកាសអន្តរក្រសួងលេខ ១៧០ ប្រក.អន្តរក្រ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម។

៣-ស្នើសុំរាជរដ្ឋាភិបាល ជាពិសេស គ.ជ.អ.ប ជំរុញ និងលើកទឹកចិត្តដល់សាមីក្រសួងពាក់ព័ន្ធ ធ្វើការពន្លឿនការផ្ទេរមុខងារ និងសេវាសំខាន់ៗ ជាពិសេសសេវារដ្ឋបាលទាំងអស់ ឲ្យដល់រដ្ឋបាលថ្នាក់ ក្រោមជាតិក្នុងបំណាច់ឆ្នាំ២០២០។ ទន្ទឹមនេះស្នើពង្រឹង និងពង្រីកបរិមាណ និងគុណភាពនៃការិយាល័យច្រកចេញចូលតែមួយ (One Window Service) ដល់គ្រប់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងនៅតាមក្រសួងទាំងឡាយក្នុងបំណាច់ឆ្នាំ២០២១ខាងមុខ។

៤-បង្កើនប្រសិទ្ធភាព ប្រសិទ្ធផល និងភាពស៊ីសង្វាក់គ្នាក្នុងកំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

៥-ស្នើដល់រាជរដ្ឋាភិបាល ពន្លឿនការអនុវត្តអភិក្រមភាពជាដៃគូពហុភាគី(រដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន) តាមរយៈការពង្រឹង និងពង្រីកគុណភាពយន្តការក្រុមការងារបច្ចេកទេសចម្រុះគ្រប់ភាគី (TWG) និងគណៈកម្មាធិការគ្រប់គ្រង (PSC) គណនេយ្យភាពសង្គមនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៦-លើកទឹកចិត្តដល់រាជរដ្ឋាភិបាល ពន្លឿនការអនុមត័ច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន និងអនុវត្ត ឲ្យមានប្រសិទ្ធភាពទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ រាជរដ្ឋាភិបាលត្រូវពង្រឹងឡើងវិញនូវសេរីភាព សារព័ត៌មាន ដោយបង្កលក្ខណៈឲ្យប្រព័ន្ធផ្សព្វផ្សាយឯករាជ្យរបស់សង្គមស៊ីវិលអាចដំណើរការឡើងវិញ។

៧-ស្នើដល់រាជរដ្ឋាភិបាលពិនិត្យ និងធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែន រដ្ឋាភិបាល ជាពិសេសមាត្រា៨ មាត្រា៩ មាត្រា២៤ និងមាត្រាមួយចំនួនទៀត។ ជាមួយគ្នានេះស្នើឲ្យមាន សេចក្តីពន្យល់អត្ថន័យ និងនិយមន័យមាត្រាមួយចំនួននៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលឲ្យកាន់តែច្បាស់ ដើម្បីជៀសវាងការយល់ផ្សេងគ្នា និងបកស្រាយខុសៗគ្នា។

ជាមួយនេះផងដែរ នាពេលថ្មីនេះ ក្រសួងមហាផ្ទៃក៏បានដាក់ចេញនូវសេចក្តីជូនដំណឹងលេខ ៥៩៨ សជណ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ ដោយបានកំណត់ឲ្យរដ្ឋបាលរាជធានី ខេត្ត ត្រូវរៀបចំវេទិកាពិគ្រោះយោបល់សម្រាប់ឆ្នាំ២០១៩ ដោយមានការចូលរួមពីមន្ទីរជំនាញនានា អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ រដ្ឋបាល ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ព្រមទាំងសមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍នានានៅមូលដ្ឋាន។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី !**

ក្នុងនាមក្រសួងមហាផ្ទៃ និងក្នុងនាម**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ខ្ញុំសូមផ្តល់ជាអនុសាសន៍មួយចំនួន ដើម្បីបន្តរួមគ្នាធ្វើកិច្ចសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋាន ជាមួយសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាអង្គការសង្គមស៊ីវិលទាំងអស់ ដោយត្រូវយកចិត្តទុកដាក់ក្នុងការធ្វើសកម្មភាពរបស់ខ្លួនតាមរយៈកិច្ចការមួយចំនួនដូចខាងក្រោម៖

**១.**សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ត្រូវយកចិត្តទុកដាក់ក្នុងការបំពេញកាតព្វកិច្ចតាមការកំណត់ដោយច្បាប់ ព្រមទាំងធ្វើសកម្មភាពឲ្យបានត្រឹមត្រូវស្របតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាជាធរមាន និងលក្ខន្តិកៈរបស់ខ្លួនដែលបានតម្កល់ទុកនៅក្រសួងមហាផ្ទៃ។ ទន្ទឹមនេះ អង្គការមិនមែនរដ្ឋាភិបាលក្នុង

ស្រុក អង្គការមិនមែនរដ្ឋាភិបាលបរទេស ឬសមាគមបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតចំពោះគ្រប់គណបក្សនយោបាយនៅព្រះរាជាណាចក្រកម្ពុជា។

**២.**សមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចបន្តកិច្ចសហការជាមួយរាជរដ្ឋាភិបាលជាពិសេសរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តនូវយុទ្ធសាស្ត្រគណនេយ្យភាពសង្គម ដើម្បីពង្រឹងគណនេយ្យភាព របស់រដ្ឋបាលសាធារណៈ រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។

**៣.**ស្នើសុំឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមកិច្ចសហការ ព្រមទាំងផ្តល់ទិន្នន័យ សំណុំឯកសារពាក់ព័ន្ធនឹងការតម្កល់ និងការចុះបញ្ជីនៅក្រសួងមហាផ្ទៃ ទៅក្នុងទម្រង់ទិន្នន័យ (សលាកប័ត្រព័ត៌មាន) ជាមួយក្រុមការងាររបស់ក្រសួងមហាផ្ទៃ និងអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា(ccc) ដែលបានព្រមព្រៀងគ្នាធ្វើកិច្ចសហការធ្វើជំរឿនសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានតម្កល់សំណុំឯកសារ និងចុះឈ្មោះក្នុងបញ្ជីនៅក្រសួងមហាផ្ទៃ។

គោលបំណងសំខាន់នៃការធ្វើជំរឿននេះ គឺដើម្បីពិនិត្យឡើងវិញនូវចំនួនពិតប្រាកដរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានកំពុងដំណើរការ និងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ជាចុងបញ្ចប់នេះ ក្នុងនាមថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសង្ឃឹមថា **ទិវាសង្គមស៊ីវិល**នេះ នឹងប្រព្រឹត្តទៅដោយទទួលបាននូវលទ្ធផលល្អប្រសើរ ដោយមានការជជែកពិភាក្សាគ្នាយ៉ាងផុលផុស និងទូលំទូលាយរវាងអ្នកពាក់ពន្ធនានា តំណាងស្ថាប័ននានានៃ រាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលបន្ថែមទៀត ក្នុងការពង្រឹងភាពជាដៃគូឲ្យកាន់តែខ្លាំងក្លាឡើងលើគ្រប់វិស័យ ដើម្បីបន្តអភិវឌ្ឍសេដ្ឋកិច្ច សង្គម សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងសូមប្រសិទ្ធពរជ័យជូនគណៈអធិបតី ឯកឧត្តម លោកជំទាវ លោកស្រី អស់លោកទាំងអស់សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមប្រកាសបើកកិច្ចប្រជុំស្តីពី " **ទិវាសង្គម-ស៊ីវិល** " ក្រោមប្រធានបទ **ភាពជាដៃគូប្រកបដោយបរិយាប័ន្នសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងប្រកបដោយចីរភាព** ចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**